ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

# សេចក្ដីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ ឯកឧត្តម *Pehin Datu Lailaraja Major General (Retired) Dato Paduka Seri Haji Awang Halbi Bin Haji Mohd Yussof* រដ្ឋមន្ត្រីទី២ ក្រសួងការពារជាតិប្រ៊ុយណេដារូសាឡឹម **សម្ដេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារជាតិ ចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១៥ (15th ADMM) កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក លើកទី៨ (8th ADMM Plus) និងកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន **ពីថ្ងៃទី១៥ ដល់១៦ ខែមិថុនា ឆ្នាំ២០២១តាមប្រព័ន្ធវីដេអូ។**

១. នៅក្នុង**កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១៥ (15th ADMM)** រដ្ឋមន្ត្រីការពារជាតិអាស៊ាន បានចូលរួមអនុម័តឯកសារទស្សនទាន ឯកសារពិភាក្សា និងវិធានប្រតិបត្តិការនិយាម សរុបចំនួន ៩ រួមមាន ឯកសារទស្សនទានចំនួន ៤ ត្រូវបានអនុម័ត ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ផ្ទាល់ក្នុងអាស៊ាន ការពង្រឹងការភ្ជាប់ទំនាក់ទំនងអាស៊ានជាមួយដៃគូខាងក្រៅ ការបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខព័ត៌មានវិទ្យា ព្រមទាំងការបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មានវិទ្យា សម្រាប់វិស័យការពារជាតិអាស៊ាន។ អង្គប្រជុំបានធ្វើការកត់សម្គាល់លើឯកសារចំនួន ២ និងឯកភាពលើឯកសារបំពេញបន្ថែមចំនួន ៣។ ឯកសារទស្សនទានទាំងនោះ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន ឱ្យកាន់តែមានប្រសិទ្ធភាព ពង្រឹងមជ្ឈភាពអាស៊ាន និងយន្តការពាក់ព័ន្ធផ្សេងៗដែលដឹកនាំដោយអាស៊ាន។ រដ្ឋមន្ត្រីការពារជាតិអាស៊ាន ក៏បានអនុម័តលើប្រកាសបេជាសេរីបេហ្គាវ៉ាន់ ក្នុងការប្រារព្ធខួបលើកទី១៥ របស់រដ្ឋមន្ត្រីការពារជាតិអាស៊ានឆ្ពោះទៅកាន់ ការត្រៀមជាស្រេចសម្រាប់អនាគតសន្តិភាព និងវិបុលភាពអាស៊ាន ដែលជាឯកសារដ៏សំខាន់មួយរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន ដោយផ្តោតលើការពង្រឹងមជ្ឈភាពអាស៊ាន និងការលើកកម្ពស់កិច្ចសប្រតិបត្តិការការពារជាតិ ក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។

នៅក្នុងឱកាសនោះ សម្តេចពិជ័យសេនា បានថ្លែងនូវការកត់សំគាល់ខ្លីមួយ វាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងរបស់ឧត្តមមន្ត្រីការពារជាតិអាស៊ាន (ADSOM) និងក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន (ADSOM WG) ក្នុងការជំនះលើឧបសគ្គទាំងឡាយដើម្បី



ក្រសួងការពារជាតិ មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥)៧៩ ៧៧៧ ៧៨៨, ទូរសារ: (៨៥៥) ២៣ ៨៨៨ ៨៦៥

សម្រេចបាននូវការឯកភាពគ្នាលើឯកសារទាំងអស់។ សម្ដេចក៏បានគូសបញ្ជាក់ផងដែរថា នៅពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំ ADMM ឆ្នាំ២០២២ កម្ពុជានឹងដាក់បញ្ចូលនូវទស្សនវិស័យជាយុទ្ធសាស្ត្រមួយចំនួន ដែលនៅក្នុងនោះមាន ការពង្រឹងតួនាទីរបស់កងទ័ពនៃបណ្ដាប្រទេសអាស៊ាន ដើម្បីឆ្លើយតបទៅនឹងជំងឺរាតត្បាតឆ្លងព្រំដែន និងការពង្រឹងយន្តការគាំទ្រស្ត្រីអាស៊ាន ក្នុងប្រតិបត្តិការរក្សាសន្តិភាព។

អង្គប្រជុំក៏បានអនុម័តលើគោលការណ៍នៃកិច្ចប្រជុំ ADMM-បូក ជារៀងរាល់ឆ្នាំ និងការឯកភាពឱ្យមានកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-អូស្ត្រាលី និងកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-សាធារណរដ្ឋកូរ៉េ នៅក្នុងកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការពារជាតិអាស៊ាន នៅខែវិច្ឆិកា ឆ្នាំ២០២១។

២. នៅរសៀលថ្ងៃដដែលក៏មាន **កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ចិន (ASEAN-China Defence Ministers' Informal Meeting)**។ រដ្ឋមន្ត្រីការពារជាតិចិន និងរដ្ឋមន្ត្រីការពារជាតិអាស៊ាន បានវាយតម្លៃខ្ពស់លើសមិទ្ធផល និងបទពិសោធន៍ជោគជ័យនៃកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន រយៈពេលបីទសវត្សរ៍កន្លងទៅ ព្រមទាំងពិនិត្យមើលសំណើកិច្ចសហប្រតិបត្តិការការពារជាតិ ក្នុងឱកាសនៃការប្រារព្ធខួប ៣០ឆ្នាំ នៃការបង្កើតទំនាក់ទំនងកិច្ចសន្ទនាអាស៊ាន-ចិន និងធ្វើការផ្លាស់ប្ដូរទស្សនៈពីស្ថានភាពអន្តរជាតិ និងតំបន់។

ភាគីទាំងពីរ (អាស៊ាន-ចិន) បានទទួលស្គាល់អំពីតួនាទីរបស់ប្រទេសចិននៅក្នុងកិច្ចខិតខំប្រឹងប្រែងពង្រឹងស្ថិរភាពនៅក្នុងតំបន់ ការអភិវឌ្ឍសេដ្ឋកិច្ច និងការប្រយុទ្ធប្រឆាំងជាមួយការគម្រាមកំហែងរួម ជាពិសេសការប្រយុទ្ធជាមួយកូវីដ-១៩។ ភាគីទាំងពីរ ក៏បានវាយតម្លៃខ្ពស់ចំពោះភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងចិន និងផ្ដល់ការគាំទ្រដល់ការធ្វើជាសហប្រធានរបស់កម្ពុជា និងចិនសម្រាប់ក្រុមការងារជំនាញ ស្ដីពីសកម្មភាពកំចាត់មីនមនុស្សធម៌ក្នុងជុំទី៤។ ភាគីទាំងពីក៏បានជម្រុញឱ្យមានការបញ្ចប់ក្រមប្រតិបត្តិ ស្ដីពីសមុទ្រចិនខាងត្បូងឱ្យបានឆាប់។

៣. នៅក្នុង**កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូកលើកទី៨ (8th ADMM-Plus)** រដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក បានផ្លាស់ប្ដូរទស្សនៈ ស្ដីពីបរិយាកាសសន្តិសុខតំបន់ និងអន្តរជាតិតាមការយល់ឃើញ និងការកំណត់អាទិភាពរបស់ប្រទេសនីមួយៗ ដូចជាបញ្ហាឥណ្ឌូ-ប៉ាស៊ីហ្វិក បញ្ហាសមុទ្រចិនខាងត្បូង ស្ថានភាពនៅប្រទេសមីយ៉ាន់ម៉ា បញ្ហាភេរវកម្ម បញ្ហាឧបទ្វីបកូរ៉េ បញ្ហាបម្រែបម្រួលអាកាសធាតុ និងបញ្ហាប្រកួតប្រជែងរវាងមហាអំណាចក្នុងតំបន់ជាដើម។ **សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** ក៏បានចូលរួមចែករំលែកទស្សនៈ ដោយបានលើកបញ្ហាសន្តិសុខ ដែលកំពុងប្រឈមមួយចំនួន ដូចជាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ បញ្ហាភេរវកម្ម ជាពិសេសពីគុណតម្លៃនៃនយោបាយឈ្នះ ឈ្នះ របស់សម្ដេចតេជោ ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមស៊ីវិល និងនាំមកនូវឯកភាពពេញលេញនៅកម្ពុជា។ កម្ពុជា ក៏បានបញ្ជាក់អំពីការគាំទ្រលើវិស័យរក្សា

សន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ដែលកម្ពុជាបានចូលរួមយ៉ាងសកម្មតាំងពីឆ្នាំ ២០០៦ មក ជាពិសេស ការប្តេជ្ញាចិត្តក្នុងការជម្រុញឱ្យមានការចូលរួមពីស្ត្រីកាន់តែច្រើនក្នុងបុព្វហេតុរក្សាសន្តិភាពនេះ។

ជាមួយគ្នានេះដែរ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក ក៏បានអនុម័តសេចក្តីប្រកាសបេនដាសេរីបេហ្គាវ៉ាន់ ដោយរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក ក្នុងការប្រារព្ធខួបលើកទី១៥ កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន ស្តីពីការត្រៀមជាស្រេចសម្រាប់អនាគត សន្តិភាព និងវិបុលភាពអាស៊ាន ដែលផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែង លើវិស័យការពារជាតិរវាងរដ្ឋសមាជិកអាស៊ាន និងប្រទេសបូក។

អង្គប្រជុំបានអនុម័តលើគោលការណ៍នៃកិច្ចប្រជុំប្រចាំឆ្នាំនៃ ADMM-បូក ការបន្លាយអាណត្តិរបស់ក្រុមការងារជំនាញ (EWG) ជុំទី៤ ដល់ត្រីមាសទី១ ឆ្នាំ២០២៤ និងការព្រមអោយមានសន្និសីទ ស្តីពីកិច្ចប្រជុំការងារពិសេស អំពីការគម្រាមកំហែងដោយគីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម ដែលស្នើឡើងដោយសិង្ហបុរី។

ថ្ងៃពុធ ៧កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១